# របាយការណ៍នៃការវិវត្តន៍ទីផ្សារស្រូវអង្ករ

(ពីខែមករា ដល់ ខែកញ្ញា២០០៩)

## I-សេចក្តីផ្តើម

ការវិវត្តន៍នៃទីផ្សារស្រូវអង្ករ ត្រូវបានចងក្រងជារបាយការណ៍ប្រចាំខែដែលច្របាច់បញ្ចូលជារបាយការណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ ព័ត៌មានទីផ្សារស្រូវអង្ករប្រមូលមកពីប្រទេសវៀតណាម ថៃ និងទីផ្សារអន្តរជាតិដ៏ទៃទៀតតាមរយៈប្រពន្ធ័អ៊ីធើណេតដើម្បីជាប្រយោជន៍សម្រាប់ជាគំនិតក្នុងការធ្វើជំនួញស្រូវអង្កររបស់សហគ្រាសអង្គការសេដាក។

កាលពីប៉ុន្មានខែកន្លងទៅ សហគ្រាសអង្គការសេដាកបានលក់អង្ករសំរូបផ្កាម្លិះទៅ៤ក្រុមហ៊ុនក្នុងស្រុកមួយ ចំនួន១៥តោនដែលនាំទៅកាន់ប្រទេសម៉ាឡេស៊ី។ ក្នុងពេលថ្មីៗនេះ សហគ្រាសអង្គការសេដាកភ្ជាប់កិច្ចសន្យាដោយផ្ទាល់ក្នុងការដឹកជញ្ជូនអង្ករផ្កាម្លិះទៅកាន់សហរដ្ឋអាមេរិកក្នុងបរិមាណ២កុងតេនឺរ(2containers )ប្រមាណ៤០តោនជាលើកដំបូង។ ជាទស្សនៈវិស័យ សហគ្រាសអង្គការសេដាកនឹងមានការនាំចេញអង្ករសរីរាង្គច្រើនថែមទៀតទៅកាន់ទីផ្សារអន្តរជាតិ។

តាមការវាយតំលៃ គុណភាពអង្កររបស់កម្ពុជានឹងអាចបំពេញតាមបទដ្ឋានពាណិជ្ជកម្មសំរាប់ទីផ្សារនាំចេញក្នុងពេលឆាប់ៗនេះ។ ក្នុងពេលជាមួយគ្នានេះ សហគ្រាសអង្គការសេដាកនឹងមានលទ្ធភាពបំពេញនូវតំរូវការតាមកិច្ចសន្យាដើម្បីនាំទៅអង្ករសរីរាង្គទៅកាន់សហគមន៍អឺរ៉ុបជាមួយក្រុមហ៊ុនអាល្លឺម៉ង់។ វាជាការចាំបាច់ណាស់ដើម្បីប្រមូលព័ត៌មានទីផ្សារស្រូវអង្ករថ្មីៗទាំងនៅលើទីផ្សារអន្តរជាតិនិងទីផ្សារក្នុងស្រុក។

## II-ការប្រមើលមើលទីផ្សារស្រូវអង្ករ

### គោលដៅនាំចេញមាសសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ

បើតាមការរំពឹងទុកនៅដើមឆ្នាំ២០១០ កម្ពុជានឹងនាំចេញអង្ករក្រអូបរបស់ខ្លួនចំនួន ៥0,000តោនទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប វាជាលើកទីមួយហើយចាប់តាំងពីឆ្នាំ១៩៩៣ នៃរាជាណាចក្រកម្ពុជាទី២។ កាលពីពេលថ្មីៗកន្លងមក អង្ករកម្ពុជាក៏បាននាំចេញទៅកាន់បណ្តាប្រទេសនៅទ្វីបអឺរ៉ុបដែរដូចជាបារាំង អាល្លឺម៉ង់ជាដើមប៉ុន្តែក្នុងបរិមាណតិចតួចនេះ បើយោងតាមប្រសាសន៍របស់លោកភូ ពុយប្រធានសមាគមន៍រោងម៉ាស៊ីនកិនស្រូវកម្ពុជា។ គាត់បានបន្ថែមទៀតថាកម្ពុជាក្នុងពេលបច្ចុប្បន្ននេះមានមជ្ឈមណ្ឌលកែឆ្នៃអង្ករដែលអាចផលិតអង្ករដែលមានគុណភាពល្អលេខមួយដើម្បីបំពេញតំរូវការនាំចេញ។

លោកបណ្ឌិតយ៉ង សាំងកុមារប្រធានមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជាមានសុទិដ្ឋិនិយមនៅពេលដែលកម្ពុជាមានសមត្ថភាពផលិតអង្ករលក្ខណៈស្តង់ដារអាចនាំចេញទៅកាន់ទីផ្សារអឺរ៉ុបដែលប្រការនេះវាផ្តល់ផលប្រយោជន៍ក្នុងការបង្កើនសេដ្ឋកិច្ចជាតិជាពិសេសកសិករតូចតាច។

លោកបណ្ឌិតបានបន្ថែមទៀតថាការបើកចំហទីផ្សាររបស់អឺរ៉ុបខាងផ្នែកទីផ្សារអង្ករគឺជួយប្រទេសក្រីក្រដូចជាប្រទេសកម្ពុជាដោយមិនតំរូវឲបង់ពន្ធពីសហគមន៍អឺរ៉ុប។ យ៉ាងណាមិញ លោកបានបន្តទៀតថា អឺរ៉ុបទាមទារស្តង់ដាគុណភាពអង្ករខ្ពស់ណាស់ទើបអាចទទួលយកបាន ដូច្នេះបើកម្ពុជាមានលទ្ធភាពផលិតអង្ករមានគុណភាពខ្ពស់បាន វាជាការប្រពៃមួយសំរាប់ជួយស្តារប្រទេសកម្ពុជាក្នុងវិស័យកសិកម្ម។

លោកបណ្ឌិតបានបញ្ជាក់ថា "អ្វីដែលសំខាន់តើយើងអាចមានលទ្ធភាពផលិតអង្ករតាមស្តង់ដាររបស់គេឬអត់ហើយខ្ញុំរំពឹងថាប្រសិនបើមានទីផ្សារធំទូលាយនិងតម្លៃសមរម្យល្អយើងជឿជាក់ថាវានឹងជួយជំរុញឲកសិករបង្កើននូវការដាំដុះដំណាំស្រូវបន្ថែមទៀត"។

## ការនាំចេញអង្ករផ្កាម្លិះសរីរាង្គរបស់កម្ពុជាជាលើកដំបូងទៅកាន់សហរដ្ឋអាមេរិក

សហគ្រាសអង្គការសេដាកពិតជាបោះមួយជំហានទៅមុខទៀតទៅកាន់ទីផ្សារអន្តរជាតិប្រសិនបើគំរោងនាំចេញរបស់ខ្លួនទៅកាន់សហរដ្ឋអាមេរិកបានជោគជ័យ។ នេះគឺជាលើកទី១ក្នុងការនាំអង្ករសំរូបផ្កាម្លិះសរីរាង្គរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក។ ឥឡូវនេះកិច្ចព្រមព្រៀងរវាងសហគ្រាសអង្គការសេដាកនិងក្រុមហ៊ុន Lotus របស់អាមេរិកស្ទើរតែសំរេចទាំងស្រុងទៅហើយពីព្រោះថាទាំងគុណភាពតាមស្តង់ដារនិងបញ្ហាសំភារៈវេចខ្ចប់ព្រមទាំងតំលៃ (FOB) ត្រូវបានឯកភាពរួចរាល់អស់ហើយ។

ទាំងតំលៃនាំចេញ និងបញ្ហាផ្សេងៗត្រូវបានដោះស្រាយដូច្នេះគំរោងការកិនស្រូវ និងការនាំចេញនឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ។ ជាមោទនភាពសំរាប់សហគ្រាសអង្គការសេដាកដែលបោះជំហានទៅមុខដើម្បីផ្សារភ្ជាប់កសិករកម្ពុជាជាមួយទីផ្សារអន្តរជាតិដែលជាគោលបំណងរបស់កសិករដៃគូរដែលរងចាំជាយូរមកហើយ។ នេះគ្រាន់តែជំហានដំបូងប៉ុណ្ណោះក្នុងការបោះជំហានឆ្ពោះទៅកាន់ទីផ្សារអង្ករអន្តរជាតិ ពីព្រោះសហគ្រាសអង្គការសេដាកនៅជាប់កិច្ចសន្យា ក្នុងការនាំចេញអង្ករសរីរាង្គកម្ពុជា ទៅកាន់ទីផ្សារសហគមន៍អឺរ៉ុបជាមួយក្រុមហ៊ុន Rickmers ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយនេះ។

## ការវិវត្តន៍ទីផ្សារស្រូវអង្ករក្នុងស្រុក

ចាប់តាំងពីដើមឆ្នាំ ២០០៩ ទីផ្សារស្រូវអង្ករក្នុងស្រុកហាក់ដូចជានៅថេរបើធៀបនឹងតំលៃកាលពីឆ្នាំ២០០៨ដែលកើនឡើងយ៉ាងគំហុកក្នុងអំឡុងពេលខែមិនានិងមេសាហើយបានធ្លាក់ចុះបន្តិចមកវិញនៅខែឧសភា។ នេះសបញ្ជាក់ឲឃើញថាស្រូវអង្ករនៅក្នុងស្តុកនៃប្រទេសនិមួយៗមានគ្រប់គ្រាន់ហើយ បន្ទាប់ពីពេលវេលាដ៏លំបាកក្នុងកំឡុងពេលខែមិនានិងមេសា។ បន្ទាប់ពីពេលនោះមកពុំសូវមានការបញ្ជាទិញក្នុងទំហំច្រើនទេនៅលើទីផ្សារអន្តរជាតិដែលប្រទេសផលិតស្រូវដូចជាប្រទេសថៃ និងវៀតណាមសល់ស្រូវច្រើនក្នុងស្តុករបស់ពួកគេដោយសារតែទិន្នផលស្រូវប្រមូលបានច្រើន។

ជាការពិតណាស់ ទីផ្សារស្រូវអង្ករនៅកម្ពុជារងឥទ្ធិពលពីប្រទេសជិតខាងដូចជាថៃ និងវៀតណាម។ ជាធម្មតានៅរដូវច្រូតកាត់ឬក្រោយបន្តិចបន្តួច ឈ្មួញបានមកទិញស្រូវពីប្រទេសកម្ពុជានាំចេញទៅប្រទេសជិតខាងហើយកិនលក់នៅទីផ្សារអន្តរជាតិ។ ដូចកាលពីរដូវច្រូតកាត់២០០៨ ស្រូវត្រូវបានដឹកចេញពីប្រទេសកម្ពុជាប្រមាណ១លានតោនដោយនាំទៅកាន់ប្រទេសវៀតណាម។

បើទោះជាបរិមាណស្រូវដ៏ច្រើនលើសលប់ត្រូវបានដឹកចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាម(មិនទាន់មានរបាយការណ៍ជាក់លាក់ពីបរិមាណស្រូវដឹកទៅប្រទេសថៃទេ)ប៉ុន្តែវាមិនបានធ្វើឲតម្លៃស្រូវនៅប្រទេសកម្ពុជាកើនឡើងនោះទេ។ តំលៃស្រូវធម្មតាប្រែប្រួលពី៦៨០រៀលទៅ៨៨០រៀលក្នុង១គីឡូរី ឯពូជស្រូវអ៊ីរ៉ែរមានតម្លៃពី៦៥០ទៅ៨០០រៀលក្នុង១គីឡូ ហើយស្រូវផ្កាម្លិះតំលៃពី៩៧០ទៅ១៥០០រៀលក្នុង១គីឡូ ចាប់ពីខែធ្នូ២០០៨រហូតដល់ខែសីហា២០០៩នេះ។




ក្រាហ្វិកខាងក្រោមបង្ហាញពីបម្រែបម្រួលតំលៃអង្ករនៅទីក្រុងភ្នំពេញ។ ព័ត៌មានអំពីតំលៃអង្ករនេះប្រមូលពីកន្លែងលក់ដុំសំខាន់ៗបីកន្លែងគឺផ្សារដើមគរ ផ្សារអូឬស្សីនិងកន្លែងលក់ដុំនៅមុខស្ថានីយ៍រថភ្លើងក្រុងភ្នំពេញ។




បើពិនិត្យក្រាហ្វិកខាងលើ តំលៃអង្ករស្មើរតែថេរចាប់ពីខែមករាដល់ខែកញ្ញាបើទោះបីមានការប្រែប្រួលតិចតួចនៅចុងខែមិថុនាតែមិនមែនបណ្តាលមកពីតំរូវការទីផ្សារទេតែវាប្រែប្រួលដោយសារការទូទាត់ទៅនឹងការចំណាយផ្សេងៗដូចជាចំណាយលើការទុកដាក់និងតម្លៃការប្រាក់ប៉ុណ្ណោះ។សូមពិនិត្យមើលក្រាហ្វិកនៃបម្រែបម្រួលតំលៃស្រូវខាងក្រោម៖




*(F: ការប្រមើលមើល) (ទិន្នន័យបានមកពីអង្គការសេដាក)*

## III-ការប្រមើលមើលទីផ្សារស្រូវអង្ករនៅលើទីផ្សារអន្តរជាតិ

### សមាគមស្បៀងអាហារនិយាយថាការបណ្តាក់ទុនរួមគ្នាជាមួយកម្ពុជាជាការចាំបាច់

ប្រទេសកម្ពុជាមានសក្តានុពលផ្នែកកសិកម្ម បើយោងទៅលើផ្ទៃដីកសិកម្មដ៏ធំធេង។ ដោយសារតែកង្វះខាតបច្ចេកទេសទំនើប កសិករកម្ពុជាប្រឈមមុខនឹងទិន្នផលស្រូវទាបតែទោះបីយ៉ាងណាប្រទេសកម្ពុជាផលិតស្រូវលើសសំរាប់នាំចេញទៅកាន់ប្រទេសវៀតណាម និងថៃក្រៅប្រព័ន្ធ យោងតាមប្រសាសន៍របស់លោកអនុប្រធានសមាគមន៍ស្បៀងអាហាររបស់វៀតណាម។ លោកបានបន្តទៀតថាប្រទេសកម្ពុជានឹងក្លាយជាប្រទេសនាំចេញអង្ករច្រើនដូចប្រទេសវៀតណាមដែរប្រសិនបើការនាំចេញក្រៅប្រព័ន្ធត្រូវបានទប់ស្កាត់កំឡុងពេលនិងក្រោយពេលច្រូតកាត់។

កាលពីកិច្ចប្រជុំក្នុងខែសីហាកន្លងទៅរវាងមន្ត្រីកម្ពុជានិងវៀតណាមបានពិភាក្សាគ្នាពីលទ្ធភាពនៃការរកស៊ីរួមគ្នាដើម្បីជំរុញការនាំចេញអង្ករពីប្រទេសកម្ពុជា។ គំរោងការរកស៊ីរួមគ្នានេះបានបង្កឲមានការរិះគន់ក្នុងចំណោមកសិករវៀតណាម ដែលចង់ឲរដ្ឋាភិបាលរបស់ខ្លួនផ្តោតការនាំចេញអង្ករដែលផលិតក្នុងស្រុក។

### វៀតណាមលុបចោលការកំណត់បរិមាណនាំចេញ

ប្រព័ន្ធគ្រប់គ្រងការនាំអង្ករចេញរបស់វៀតណាមនឹងត្រូវធ្វើការកែលំអរ និងប្រព័ន្ធកំណត់កូតានាំអង្ករចេញនឹងត្រូវលុបចោលដើម្បីសំរួលដល់ទីផ្សារនាំចេញ បើយោងតាមសំដីរបស់អនុរដ្ឋមន្ត្រីកសិកម្ម និងអភិវឌ្ឍជនបទប្រទេសវៀតណាម លោក Bui Ba Bong។ កូតានាំអង្ករចេញសំរាប់ឆ្នាំនេះ ដំបូងឡើយតែ ៥.២លានតោន តែប៉ុណ្ណោះ ប៉ុន្តែកាលពីខែកន្លងទៅអនុរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មលោក Do Huu Hao បានអះអាងថាថាវៀតណាមនឹងជំរុញការនាំចេញនៅក្នុងឆ្នាំនេះឲឡើងដល់៧លានតោន។ មកទល់ពេលឥឡូវនេះអង្ករប្រមាណ៤.៧លានតោនត្រូវបានដឹកជញ្ជូនរួចរាល់ហើយនៅក្នុងរយៈពេល៨

ខែដើមឆ្នាំនេះប្រហែល ៤៣ភាគរយច្រើនជាងឆ្នាំកន្លងទៅ។ កាលពីឆ្នាំកន្លងទៅបរិមាណស្រូវនាំចេញបានប្រមាណតែ ៤,៦៥លានតោនប៉ុណ្ណោះហើយចំនួននេះឡើងដល់កំរិតខ្ពស់បំផុតគឺ៥,១៧លានតោននៅក្នុងឆ្នាំ២០០៥។

## "ការច្បាមយកដី"សំរាប់ផលិតកម្មស្រូវដើម្បីបំពេញតំរូវការ

ដើម្បីបំពេញនូវតំរូវការបច្ចុប្បន្ន និងអនាគត ចំណាប់អារម្មណ៍ក្នុងពេលថ្មីៗនេះក្នុងការ "ច្បាមយកដី" ឬក៏ការទទួលយកជាអន្តរជាតិដើម្បីលែលកដីសំរាប់ផលិតស្រូវបានចាប់ផ្តើមដោយសារមើលឃើញពីការគំរាមកំហែងនៃការផ្គត់ផ្គង់ស្រូវអង្ករមិនទាន់គ្រប់គ្រាន់។ "ដើម្បីឲងាយយល់គឺពុំមានស្រូវអង្ករគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតមនុស្សលោក" បើតាមសំដីរបស់លោកបណ្ឌិត Robert Zeigler អគ្គនាយកវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ(IRRI)។

ដើម្បីបំពេញនិងរក្សាតំលៃស្រូវឲនូវត្រឹម៣០០ដុល្លាអាមេរិកក្នុង១តោន យើងត្រូវផលិតបន្ថែមពី៨ទៅ១០លានតោនលើសឆ្នាំកន្លងទៅសំរាប់២០ឆ្នាំទៅមុខ។ បើតាមគំនិតនេះកសិករក្រីក្រអាចមានលទ្ធភាពរកប្រាក់ចំណេញបានរីឯអ្នកបរិភោគដែលមានជីវភាពក្រីក្រក៏មានលទ្ធភាពទិញផងដែរ។

## រដ្ឋាភិបាលថៃមានបំណងកាត់ន្ថយស្រូវអង្ករក្នុងឃ្លាំង

រដ្ឋាភិបាលថៃមានផែនការបញ្ចេញអង្កររបស់ខ្លួនចំនួន៥០.០០០តោនពីឃ្លាំងមុនខែតុលាដើម្បីបញ្ចៀសនូវសំពាធទៅលើតំលៃស្រូវអង្ករ នៅពេលដែលរដូវច្រូតកាត់ថ្មីនឹងមកដល់នៅអំឡុងខែក្រោយនេះ។ ដោយយោងតាមប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មលោកPorntiva Nakasi បានមានអះអាងថារដ្ឋាភិបាលលោកកំពុងត្រៀមរៀបចំអន្តរាគមន៍ដើម្បីប្រមូលទិញស្រូវចំនួន២លានតោនបន្ថែមប្រសិនបើតំលៃស្រូវថ្មីធ្លាក់ចុះក្រោមតំលៃទីផ្សារ។ បច្ចុប្បន្ន រដ្ឋាភិបាលមានអង្ករក្នុងស្តុកប្រមាណ៦ទៅ៧លានតោនក្នុងឃ្លាំង។

## វៀតណាមនាំអង្ករចេញទ្វេរដងទៅកាន់ទីម័រខាងលិច

ក្រុមហ៊ុនវៀតណាមនឹងបង្កើនការនាំចេញទ្វេរដងរហូតដល់ ២០០.០០០តោន ទៅកាន់ប្រទេសទីម័រខាងលិចនៅឆ្នាំក្រោយ ក្រោមកិច្ចព្រមព្រៀងដែលចុះហត្ថលេខានៅក្នុងទីក្រុងហាណូយដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មវៀតណាម និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍របស់ទីម័រខាងលិច។ អ្វីដែលគួរឲកត់សំគាល់ អង្ករដែលទទួលទាននៅក្នុងប្រទេសទីម័រខាងលិចជាអង្ករនាំចូលទាំងអស់។ រដ្ឋមន្ត្រីទាំងពីរក៏បានព្រមព្រៀងគ្នាផងដែរដើម្បីចាប់ផ្តើមការចចារពាណិជ្ជកម្មទ្វេរភាគី។ ក្រុមហ៊ុននាំចេញអង្ករនិងសមាគមន៍ត្រូវបានលើកទឹកចិត្តដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មនិងសេដ្ឋកិច្ចទ្វេរភាគី។

## ប្រទេសនៅអាស៊ីអាគ្នេយ៍បង្កើនបរិមាណស្រូវនាំចេញ

តំបន់អាស៊ីអាគ្នេយ៍ជាតំបន់មួយដែលមានផលិតកម្មស្រូវធំជាងគេក្នុងពេលបច្ចុប្បន្ននេះ ការផ្គត់ផ្គង់ស្រូវអង្ករអាចកើនឡើងខ្លាំងនៅចុងឆ្នាំ២០០៩ហើយតំលៃអង្ករនឹងធ្លាក់ចុះមកត្រឹម ៤០០ដុល្លា ក្នុង១តោនបើយោងតាមប្រសាសន៍របស់ជំនាញការថៃ លោក Prensa Latina។

អ្នកជំនាញផ្នែកម្ហូបអាហារថៃបាននិយាយថា ការកើនឡើងការនាំចេញអង្ករកើតឡើងដោយសារតែការសំរេចចិត្តរបស់រដ្ឋាភិបាលថៃដើម្បីការពារកសិករដោយលុបបំបាត់ការទិញស្រូវដោយផ្ទាល់ពីកសិករ។ ការកើនឡើងនេះជាការឆ្លើយតបទៅនឹងការកើនឡើងបរិមាណអង្ករនាំចេញរបស់វៀតណាមដែលគេរំពឹងថានឹងកើនឡើងដល់៦លានតោននៅក្នុងឆ្នាំ២០០៩ហើយអាចនឹងកើនឡើងច្រើនថែមទៀតនៅឆ្នាំក្រោយ។ ពួកគេបានបន្ថែមថាកត្តាផ្សេងទៀតគឺការកើនឡើងផលិតកម្មស្រូវនៅប្រទេសភូមានិងកម្ពុជា។

ពួកគេរំពឹងថា តំរូវការអង្ករនៅលើទីផ្សារអន្តរជាតិនឹងកើនឡើងហើយអ្នកទិញនឹងត្រូវបានលើកទឹកចិត្តដើម្បីទិញស្តុកទុកសំរាប់ឆ្នាំ២០១០ ដោយសារតែបញ្ហាលំបាកក្នុងការ

ប្រមូលទិញកាលពីឆ្នាំ ២០០៨។ នេះជាលើកទី១ហើយដែលប្រទេសថៃដែលជាប្រទេសនាំអង្ករចេញច្រើនជាងគេបំផុតនៅលើពិភពលោក បានបោះបង់ការទិញស្រូវដោយផ្ទាល់ពីកសិករដើម្បីកែប្រែតវិយាបថទីផ្សាស្រូវអង្ករ នៅពេលដែលតំលៃអង្ករ និងផលិតផលកសិកម្មដទៃទៀតកើនឡើង។ ប្រសិនបើពុំមានគ្រោះមហន្តរាយធម្មជាតិឬគ្រោះរាំងស្ងួតទេ អង្ករថៃអាចនឹងធ្លាក់ចុះមកត្រឹម៤០០ឬ៣០០ដុល្លាក្នុង១តោននេះបើតាមការប្រមើលមើលរបស់សមាគមន៍អ្នកនាំអង្ករចេញរបស់ថៃ។

## តំលៃអង្ករនៅអាស៊ីថេរទោះបីជាមានតំរូវការ

តំលៃអង្ករធម្មតាថៃ ១០០ភាគរយ (អត់មានបាក់) មិនមានការប្រែប្រួលចាប់តាំងពីសប្តាហ៍កន្លងទៅក្នុងតំលៃ៥៣០ដុល្លាក្នុង១តោន។ តំលៃនេះជាតំលៃដែលមានការគាំទ្រពីគំរោងរបស់រដ្ឋភិបាលបើតាមអ្នកជំនួញម្នាក់បាននិយាយ។ ទោះបីយ៉ាងណាក៏ដោយ គាត់មើលមិនឃើញមានការប្រែប្រួលតំលៃអង្ករគួរឲកត់សំគាល់នៅឡើយទេនៅក្នុងស្របពេលដែលតំរូវការនូវមានកំរិត។

មានការប៉ាន់ស្មានថារដ្ឋាភិបាលថៃនឹងរក្សាស្រូវអង្ករក្នុងស្តុកប្រមាណ ៧លានតោនដែលជាចំនួនច្រើនបំផុតមិនធ្លាប់មានពីមុនមកចាប់តាំងពីរដ្ឋាភិបាលប្រមូលស្រូវអង្ករស្តុកទុក។ មកទល់ពេលនេះវាមិនទាន់បង្ហាញផែនការជាក់លាក់ចំពោះការកាត់បន្ថយស្តុកនៅឡើយទេ។ ប្រទេសថៃមកទល់ពេលនេះទើបតែនាំអង្ករចេញប្រមាណតែ ៦,២លាន តោនតែប៉ុណ្ណោះទាបជាងឆ្នាំកន្លងទៅ២៣ភាគរយដែលបាននាំចេញដល់ទៅ៨,១លានតោន។

កាលពីថ្ងៃពុធកន្លងទៅរដ្ឋាភិបាលវៀតណាមបាននិយាយថាក្រុមហ៊ុននាំចេញអង្ករធំជាងគេនៅវៀតណាមឈ្មោះ Vinafood 2 នឹងស្តុកអង្ករទុកប្រមាណ ៥០.០០០តោន សំរាប់រយៈពេល៤ខែខាងមុខដើម្បីគាំទ្រតំលៃស្រូវ។ បច្ចុប្បន្នភាពនេះ អង្ករកំរិតបាក់២៥ភាគរយរបស់វៀតណាមមានតំលៃចន្លោះពី៣៤០ទៅ៣៥០ដុល្លាក្នុង១តោនសំរាប់តំលៃដឹកជញ្ជូន

ដល់កប៉ាល់ ( FOB price )  ចំណែកឯអង្ករដែលមានគុណភាពខ្ពស់កំរិតបាក់៥ភាគរយវិញ មានតំលៃចន្លោះពី៣៩០ទៅ៤០០ដុល្លាក្នុង១តោន  តំលៃនេះមិនមានការប្រែប្រួលទេតាំងពីសប្តាហ៍កន្លងទៅ។

## បម្រែបម្រួលទីផ្សារស្រូវអង្ករនៅទីក្រុងភ្នំពេញនិងបាងកក

ក្រាហ្វិកខាងក្រោមបង្ហាញថា កាលពីដើមឆ្នាំ២០០៨  តំលៃអង្ករក្រអូបថៃទាបជាងអង្ករផ្កាម្លិះខ្មែររហូតដល់ខែមេសានិងចាប់ពីខែមិថុនារហូតដល់ខែធ្នូ២០០៨។ តែចាប់តាំងពីដើមឆ្នាំ២០០៩អង្ករក្រអូបថៃបានកើនឡើងខ្ពស់ជាងអង្ករផ្កាម្លិះខ្មែរវិញម្តងរហូតមកទល់ពេលបច្ចុប្បន្ននេះ។




## IV-សន្និដ្ឋាននិងចំណាប់អារម្មណ៍

ប្រជាជនកម្ពុជាប្រមាណ១,៨លាន គ្រួសារពឹងផ្អែកលើកសិកម្មស្រូវដែលប្រើប្រាស់ដីប្រមាណ៨០ភាគរយនៃផ្ទៃដីកសិកម្ម។  កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា១ភាគធំពឹងផ្អែកលើវិស័យកសិកម្ម។  កសិករកម្ពុជាភាគច្រើននៅតែនិយមអនុវត្តបច្ចេកទេសកសិកម្ម

បុរាណដែលផ្តល់ទិន្នផលទាបបើធៀបនឹងប្រទេសជិតខាង។ បើផ្អែកលើទីតាំងភូមិសាស្ត្រ ប្រទេសកម្ពុជាមានអំណោយផលធម្មជាតិនិងជួបប្រទះគ្រោះធម្មជាតិតិចតួចជាងគេ។

ផ្អែកលើស្ថានភាពបច្ចុប្បន្ននៃព្យុះកំបុតត្បូងកេតសាណាដែលបានបក់បោកមកលើប្រទេសជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍ដូចជាហ្វីលីពីន វៀតណាម ឡាវ និងតំបន់ខ្លះរបស់ប្រទេសកម្ពុជា ប្រាកដណាស់ផ្ទៃដីកសិកម្មរាប់ពាន់ហិកតានឹងរងផលប៉ះពាល់ដោយចៀសមិនរួច។មកត្រឹមថ្ងៃនេះមិនទាន់មានរបាយការណ៍ទិន្នន័យផ្លូវការពីផលប៉ះពាល់ដោយសារព្យុះកំបុតត្បូវនេះត្រូវបានផ្សព្វផ្សាយនៅឡើយទេ។

ជាទស្សនៈវិស័យ ទោះបីជាមានគ្រោះមហន្តរាយធម្មជាតិជាច្រើនបានវាយប្រហារមកលើតំបន់ ប៉ុន្តែវាជារឿងធម្មតាដែលគ្រោះមហន្តរាយធម្មជាតិតែងតែកើតឡើងជារៀងរាល់ឆ្នាំនៅកំឡុងខែកញ្ញានិងតុលា។ បម្រែបម្រួលអាកាសធាតុជាបញ្ហាចម្បងដែលពិភពលោកកំពុងប្រឹងប្រែងដោះស្រាយ ប៉ុន្តែស្ថានភាពទីផ្សារស្រូវអង្ករនឹងមិនមានការប្រែប្រួលធ្ងន់ធ្ងរដូចកាលពីឆ្នាំ២០០៨នោះទេ ពីព្រោះទាំងប្រទេសនាំអង្ករចេញនិងប្រទេសនាំអង្ករចូលបានត្រៀមខ្លួនយ៉ាងល្អសំរាប់ធានានូវសន្តិសុខស្បៀងរបស់ខ្លួន។

ការប្រមើលមើលតម្លៃស្រូវ វាអាស្រ័យលើទីផ្សារស្រូវអង្ករបច្ចុប្បន្ននិងការវិវត្តន៍តម្លៃស្រូវជារៀងរាល់ឆ្នាំ។ ដោយផ្អែកលើទិន្នន័យប្រមូលបានចាប់តាំងពីឆ្នាំ២០០៥ តំលៃស្រូវមិនដែលមានការប្រែប្រួលខ្លាំងដូចតំលៃអង្ករទេ វាការកើនឡើងតាមសំរួលពី ៧០០ រៀលនៅក្នុងឆ្នាំ២០០៥រហូតដល់១១០០ក្នុង១គីឡូក្នុងឆ្នាំ២០០៨សំរាប់ស្រូវផ្កាម្លិះ។ ជាសរុបមកតំលៃស្រូវផ្កាម្លិះក្នុងរដូវច្រូតកាត់ឆ្នាំ ២០០៩-២០១០ នេះអាចស្ថិតនៅចន្លោះពី ១២០០ ទៅ ១៣០០រៀលក្នុង១គីឡូ។

រៀបរៀងដោយ: លោក ឈឹម ផល្លីបុត្រ

(07/10/2009)